# អានិសង្សមហាសង្ក្រាន្ត និងជំនឿទំនាយចូលឆ្នាំថ្មី

អំពីសង្ក្រាន្ត ឬមហាសង្ក្រាន្ត ឬបុណ្យចូលឆ្នាំខ្មែរ មានអត្ថបទចុះផ្សាយជារឿយៗនៅទីផ្សេងដោយអន្ទើៗរួចមកហើយ។[1] ក្នុងអត្ថបទនេះ ខ្ញុំសូមលើកយកសេចក្តីអធិប្បាយអំពីអានិសង្សមហាសង្ក្រាន្ត ដែលមានអត្ថន័យល្អិតល្អគួរស្វែងយល់ ហើយចារជាសាស្ត្រាទេសន៍ចំនួន២ច្បាប់ តែមានសេចក្តីខ្លឹមសារដូចគ្នា ពោលគឺនិយាយពីការសាងកុសលក្នុងឱកាសមហាសង្ក្រាន្តឆ្នាំថ្មី។ សាស្ត្រាមួយច្បាប់តម្កល់នៅបណ្ណាល័យជាតិ និងមួយច្បាប់ទៀតតម្កល់នៅបណ្ណាល័យសាស្ត្រាស្លឹករឹតវត្តឧណ្ណាលោម។ សាស្ត្រាតម្កល់នៅបណ្ណាល័យជាតិ ចុះលេខបញ្ជីសារពើភណ្ឌ F.E.M.C a138 III.6 រីឯសាស្ត្រាតម្កល់នៅបណ្ណាល័យសាស្ត្រាស្លឹករឹត ចុះលេខបញ្ជីសារពើភណ្ឌ nº12 ក្នុងឆ្នាំ១៩៩២។[2]

សាស្ត្រាអានិសង្សមហាសង្ក្រាន្តតម្កល់នៅបណ្ណាល័យជាតិ គឺជាសាស្ត្រាចម្លងតាមច្បាប់ដើមនៅវត្តកំពង់ភ្នំក្រៅ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ចម្លងដោយពុទ្ធសាសនបណ្ឌិត្យ ក្នុងឆ្នាំ១៩៤៥ (រូបលេខ១-២)។ ចំណែកឯសាស្ត្រាតម្កល់នៅបណ្ណាល័យវត្តឧណ្ណាលោម មានប្រភពមកពីវត្តព្រែកឯង ស្ថិតក្នុងខេត្តកណ្តាល។[3] សាស្ត្រានេះចារដោយភិក្ខុនាម "ឧទ្ទ ថេរ ពោរ" ចារប្រគេនទៅលោកគ្រូបុទុមថេរជាម្ចាស់ទុកតព្រះសាសនាពុំមានចុះកាលបរិច្ឆេទទេ។



រូបលេខ១-២ សាស្ត្រាស្លឹករឹតអធិប្បាយអំពីអានិសង្សមហាសង្ក្រាន្ត

---

[1] ស្រី អ៊ូ, ១៩៥៩, ទំ.៤៥១-៤៥៤, ម៉ែន ប្រាថ្ន និង អាំ ធន, ១៩៩៤, ទំ.៩២-១០១, និង ហ៊ុន ឈុនតេង "សង្ក្រាន្ត និងមហាសង្ក្រាន្ត" ផ្សាយលើគំណាង https://khmercivilization.ams.com.kh/detail/6839 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

[2] ពុទ្ធសាសនបណ្ឌិត្យចុះបញ្ជីសារពើភណ្ឌលេខ Nº 1420

[3] បច្ចុប្បន្ន វត្តព្រែកឯងស្ថិតក្នុងសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# អត្ថបទ៖ អានិសង្សមហាសង្ក្រាន្ត និងជំនឿទំនាយចូលឆ្នាំថ្មី

ជាការពិត "សង្ក្រាន្ត សង្ក្រាន្តឆ្នាំថ្មី មហាសង្ក្រាន្តឆ្នាំថ្មី ចូលឆ្នាំថ្មី ឬចូលឆ្នាំខ្មែរ" ជាពិធីបុណ្យប្រពៃណីជាតិយ៉ាងសំខាន់ក្នុងសង្គមខ្មែរ ទទួលឥទ្ធិពលអារ្យធម៌នេះពីឥណ្ឌាតាំងពីបុរាណកាល។ ពាក្យ "សង្ក្រាន្ត" មានប្រភពពីពាក្យសំស្ក្រឹតថា សង្ក្រាន្ត *(saṅkrānta)* ឬ សង្ក្រាន្តិ *(saṅkrānti)* ដែលមានន័យថា ដំណើរឃ្លាតចាកទី ឬការឈានចូលដល់ ពោលគឺសំដៅដល់ដំណើរព្រះអាទិត្យចរចូលទីជួបមួយជុំនៃរាសីចក្រ។ សោតឯពាក្យ "សង្ក្រាន្ត" ឃើញមានចារឹកនៅក្នុងសិលាចារឹកខ្មែរបុរាណ យ៉ាងហោចតាំងពីដើមសតវត្សរ៍ទី១០នៃគ្រិស្តសករាជ។ ពីបុរាណមក លោកចែកសង្ក្រាន្តទៅតាមរាសីចក្រចំនួន១២ ហើយដែលមួយជុំនៃល្វែងរាសីទាំង១២ ពេញគ្រប់មួយឆ្នាំ។ ចំពោះ "មហាសង្ក្រាន្ត" ជាដំណើរចុងបំផុតនៃសង្ក្រាន្តទាំង១២ ហើយលោកកំណត់យកជាវេលាចូលឆ្នាំថ្មី ផ្លាស់ពី "មីនរាសី" ឡើងកាន់ "មេសរាសី" ពោលគឺដំណើរនៃការផ្លាស់ឆ្នាំចាស់ចូលឆ្នាំថ្មី ឬហៅទូទៅថា "ចូលឆ្នាំថ្មី"។ ទន្ទឹមនឹងនេះបើតាមព្រះរាជពិធីទ្វាទសមាស មុននឹងដល់ថ្ងៃមហាសង្ក្រាន្ត នៅក្នុងព្រះបរមរាជវាំងតែងប្រារព្ធព្រះរាជពិធីត្រស្តិសង្ក្រាន្តនៅថ្ងៃ១២ ដល់១៥ រោច ខែផល្គុន ជាកិច្ចជូនដំណើរទេវតាឆ្នាំចាស់ចេញទៅ និងទទួលទេវតាឆ្នាំថ្មីចូលមកគ្រប់គ្រងព្រះនគរ ចាប់ពីថ្ងៃមហាសង្ក្រាន្តចូលដល់ (រូបលេខ២៣)។[4]




រូបលេខ២៣ ព្រះរាជពិធីត្រស្តិសង្ក្រាន្តក្នុងព្រះបរមរាជវាំង (ប្រភព៖ ក្រសួងព័ត៌មាន)

[4] ចាប ពិន និងសហការី, ១៩៦០, ទំ.១៥៧-១៧៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក បើលើកសាស្ត្រាអានិសង្សមហាសង្ក្រាន្តទាំងពីរខាងលើមកអធិប្បាយ មានសេចក្តីសង្ខេបថា ក្នុងសម័យពុទ្ធកាលព្រះបាទបស្មិន្ទិកោសលបានទូលសួរព្រះសម្មាសម្ពុទ្ធនូវសេចក្តីថា "មហាសង្ក្រាន្តឆ្នាំថ្មីមកដល់យល់សេចក្តីពុំទៀង មានកាលឱ្យជាក្សេមក្សាន្តអស់មនុស្សម្នាប្រជារាស្ត្រផង មានកាលពុំឱ្យជាសុខជាទុក្ខក្តៅចិត្ត មានកាលឱ្យភ្លៀងល្អស្រូវអង្ករចំណីអាហារត្រកាល មានកាលក្តៅក្រហាយភ្លៀងពុំល្អស្រូវអង្ករក៏ថ្លៃ ទ្រព្យមានតម្លៃគ្រឿងប្រដាប់ ទ្រព្យបរិភោគនឹងរកពុំបាន តើដំណើរនោះដូចម្តេច?"

ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះសន្តាប់បញ្ហាចោទសួររបស់ព្រះបាទបស្មិន្ទិកោសលហើយ បានលើកហេតុជាប្រការថា ដំណើរវិបត្តិប្រែប្រួលដោយហេតុព្រះសុរិយាទេវបុត្រស្ថិតនៅមីនរាសី ចូលទៅកាន់បឋមរាសីផ្លូវគោវិថី។ បើ "ទ្រង់ឈរ" នោះមនុស្សលោកកើតអត់បាយច្រើន។ បើ "ទ្រង់កម្រើកជំរួលអាត្មា" នោះមនុស្សផងកើតទុក្ខអំពល់ ទ្រុស្តក្បត់ធ្វើជាចោរក៏សោតមានច្រើន។ បើ "ទ្រង់ចេញទៅផ្ទុំ" នោះអស់មនុស្សកើតនូវជំងឺតម្កាត់ ព្យាធិយារច្រើន។ បើ "ទ្រង់ចេញទៅគង់តម្រង់កាយជាសុខសប្បាយ" នោះអស់មនុស្សប្រុសស្រីមានព្រះមហាក្សត្រ ព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតកវី សឹងសុខក្សេមក្សាន្ត និរាសលែងទុក្ខភ័យបាយចំណីស្រូវអង្ករល្វសល្ដោកក៏ច្រើនពេកក្តាត់។ បើព្រះសុរិយាទេវបុត្រ "ជិះអស្សរាជាព្រះទីនាំង"[5] នោះនឹងកើតមានកលយុគ។ បើ "ទ្រង់ជិះរាជសីហ៍" នោះមនុស្សផងទាំងឡាយនឹងកើតក្តៅចិត្ត គិតពុំសូវស្លូតត្រង់នឹងរាជត្រកូលអម្បូរមហាក្សត្រាធិរាជ។ បើ "ទ្រង់ជិះលើដំរី" នោះនឹងមានប្រក្រតីជាសុខសប្បាយ ភ្លៀងល្អ ស្រូវអង្ករល្វសល្ដោកកកើតផាយក្តាត់។ បើ "ទ្រង់ជិះលើព្រះអគ្គី" នោះនឹងមានភ្លើងឆេះផ្ទះ ឱ្យទៅជាកង្វល់អំពល់ព្រួយចិត្ត។ បើ "ទ្រង់ជិះលើខ្យល់" នោះឆ្នាំថ្មីនឹងមានខ្យល់ព្យុះចុះមកទិសទាំងពួង។ បើ "ទ្រង់គង់លើភិមានមណ្ឌល" នោះរាស្ត្រមហាជនទាំងឡាយនឹងត្រជាក់ចិត្ត អស់ទុក្ខភ័យជំងឺតម្កាត់ក៏សះជា អ្នកដ៏ជាធំ និងរាស្ត្រក៏មានចិត្តថ្វាសទ្ធា ចង់ធ្វើបុណ្យឱ្យទានក៏ច្រើន។ សេចក្តីដែលព្រះសម្មាសម្ពុទ្ធ ឆ្លើយទៅព្រះបាទបស្មិន្ទកោសល អំពីព្រះសុរិយាទេវបុត្រដូចរៀបរាប់ខាងលើ បើមើលគំនូរតាមវត្តខ្លះ ឃើញវិចិត្រករគូររូបព្រះអាទិត្យគង់លើរាជរថទឹមគោ ទឹមគោ ទឹមរាជសីហ៍ ឬខ្លះទឹមសេះ ឬមានសាបីជាអ្នកបរផង (រូបលេខ៤-៧)។

[5] ព្រះសុរិយាទេវបុត្រទ្រង់ជិះសេះ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ២៨-៧ គំនូរព្រះអាទិត្យ ឬព្រះសុរិយាទេវបុត្រគូរនៅតាមពិតានព្រះវិហារខ្លះ*

ពាក់ព័ន្ធនឹងដំណើរនៃព្រះសុរិយាទេវបុត្រយាងចរចូលគោវិថី ក៏មានចែងនៅក្នុងសៀវភៅ "មហាសង្ក្រាន្ត" ផ្សាយជាប្រក្រតីប្រចាំឆ្នាំផងដែរ(រូបលេខ២៨-១០)។ មហាសង្ក្រាន្តប្រចាំឆ្នាំនោះ តែងរៀបរាប់គណនាវេលាសង្ក្រាន្តឆ្នាំថ្មីចូលដល់ ព្រះនាមទេពធីតាដែលនឹងយាងមករក្សាលោក និងរណ្តាប់ផ្សេងៗត្រូវរៀបទទួលទេព្តាឆ្នាំថ្មីផង។ មិនតែប៉ុណ្ណោះ នៅក្នុងសៀវភៅមហាសង្ក្រាន្តនោះសោតមានចែងទំនាយប្រចាំឆ្នាំ ជាទំនៀមដែលខ្មែរជឿពាក់ព័ន្ធនឹងទឹកភ្លៀង អាកាសធាតុ ផលដំណាំ និងជំងឺតម្កាត់ផ្សេងៗ ហាក់ពុំខុសពីអាថ៌សេចក្តីព្រះសម្មាសម្ពុទ្ធ ឆ្លើយទៅនឹងបញ្ហាកម្មរបស់ព្រះបាទបស្សិន្ទិកោសលឡើយ។ ប៉ុន្តែសេចក្តីក្នុងសៀវភៅមហាសង្ក្រាន្តតាំងពីដើមមកដល់សព្វថ្ងៃ ពុំរៀបរាប់លក្ខណៈដំណើរព្រះសុរិយាទេវបុត្រក្នុងឥរិយាបទ ឬជិះលើអ្វីដូចសេចក្តីក្នុងអានិសង្សមហាសង្ក្រាន្តទេ តែរៀបរាប់ដំណើរទេពធីតាដែលយាងចុះមក ទាំងលក្ខណៈតុបតែងព្រះកាយទេពធីតាអង្គនោះ រណ្តាប់ដង្វាយជាក្រយាស្ងោយ កេតនភណ្ឌ និងសត្វជាជំនិះ ។ល។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ៨-១០ សៀវភៅមហាសង្ក្រាន្តឆ្នាំមមី (ឆ្នាំ២០០២, ឆ្នាំ២០១៤, និងឆ្នាំ២០២៦)

សង្ខេបមក បើពិនិត្យម្តងទៀតក្នុងសេចក្តីនៃអានិសង្សមហាសង្ក្រាន្ត និងសេចក្តីជាទំនាយក្នុងសៀវភៅមហាសង្ក្រាន្ត គេឃើញមានចំណុចខ្លះគួរនឹងលើកមកពិចារណាដែរ ជាពិសេសពាក់ព័ន្ធនឹងជំនឿលើភ្លៀង ខ្យល់ ផលដំណាំ និងគ្រោះកាចផ្សេងៗប្រចាំឆ្នាំ។ ឧទាហរណ៍ជំនឿអំពីភ្លៀង ខ្មែរជឿលើសត្វដំរីថាជានិមិត្តរូបនៃភ្លៀង។ គំនិតនេះមាននិយាយក្នុងរឿងមហាវេស្សន្តរ ពេលនគរកលិង្គរាស្ត្រជួបគ្រោះរាំងស្ងួត ពួកព្រាហ្មណ៍លើកគ្នាទៅសុំដំរីមង្គលបច្ច័យនាគេន្ទ្រពីព្រះបាទស្រីវេស្សន្តរដែលគេយល់ថាជាដំរីមង្គលនាំឱ្យនគរក្សេមក្សាន្ត មានភ្លៀងធ្លាក់ល្អ ស្រូវអង្ករសណ្តែកល្ងមាសប្រាក់កែវកងកើតឡើងសម្បូរណ៍សប្បាយ។[6] ចំណែកឯការសាងកុសលបុណ្យឱ្យទាននៅថ្ងៃមហាសង្ក្រាន្តនោះ ព្រះសម្មាសម្ពុទ្ធសម្តែងថ្វាយព្រះបាទបស្សិទ្ធិកោសលថាបានអានិសង្ស១សែន ហើយបើបានធ្វើបុណ្យរម្លឹកគុណម្តាយឪពុក គ្រូអាចារ្យ ចាស់ទុំ ទំនុកបម្រុងនូវបាយទឹក សំពត់អាវមាសប្រាក់ ស្រោចស្រង់ទឹកអប់ជាដើម ឈ្មោះហៅថាតបព្រះគុណអ្នកដ៏មានគុណ។ ប្រហែលដោយហេតុជាប្រការនេះហើយ ទើបខ្មែរយើងតែងនាំគ្នាធ្វើបុណ្យឱ្យទាន ជូនម្ហូបចំណីសម្លៀកបំពាក់ប្រាក់កាស និងស្រង់ទឹកដល់អ្នកមានគុណនៅក្នុងរដូវចូលឆ្នាំថ្មីពុំដែលខាន។

[6] ញ៉ុក ថែម, ១៩៩១ [មហាយិន នឿន, រៀបរៀង], ទំ.៥០-៥២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ចាប ពិន និង សហការី

១៩៦០, *ព្រះរាជពិធីទ្វាទេសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ញ៉ុក ថែម

១៩៩១[មហាឃិន នឿន រៀបរៀងជាថ្មី], *មហាវេស្សន្តរជាតក*, វត្តខេមរពុទ្ធិការាម, ឡុងប៊ិក

ម៉ែន ប្រាង និង អាំ ឆន

១៩៩៤, "បុណ្យចូលឆ្នាំខ្មែរ", *កម្ពុជសុរិយា*, លេខ១, ឆ្នាំទី៤៨, ទំ.៩២-១០១, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ស្រី អ៊ូ

១៩៥៩, "ពិធីបុណ្យចូលឆ្នាំ", *កម្ពុជសុរិយា*, លេខ៤, ឆ្នាំទី៣១, ទំ.៤៥១-៤៥៤, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ហ៊ុន ឈុនតេង

"សង្ក្រាន្ត និងមហាសង្ក្រាន្ត" ផ្សាយលើគំហណ https://khmercivilization.ams.com.kh/detail/6839 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត